# ព្រះរាជក្រម

នស/រកម/០៤១៨/០០៦

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីអាជ្ញាបណ្ណបញ្ញាសម្រាប់សុខភាពសាធារណៈ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៨ នាសម័យប្រជុំរដ្ឋសភាលើកទី១០ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៨ នាសម័យប្រជុំពេញអង្គលើកទី១១ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

# ច្បាប់

## ស្ដីពី

# អាជ្ញាបណ្ណបញ្ជាសម្រាប់ សុខភាពសាធារណៈ

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

# ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ច្បាប់នេះមានគោលបំណងលើកកម្ពស់សិទ្ធិទទួលបាននូវផលិតផលឱសថសម្រាប់សុខភាពសាធារណៈ តាមរយៈការផ្តល់អាជ្ញាបណ្ណបញ្ជាឱ្យផលិត នាំចេញ និងនាំចូលនូវផលិតផលឱសថក្នុងកាលៈទេសៈប្រទេសជាតិមានភាពអាសន្ន ឬកាលៈទេសៈបន្ទាន់បំផុតផ្សេងទៀត ឬការប្រើប្រាស់ជាសាធារណៈមិនមានលក្ខណៈពាណិជ្ជកម្ម ឬស្ថានភាពសុខភាពសាធារណៈផ្សេងទៀតដែលកំណត់ដោយក្រសួងសុខាភិបាល ។

**មាត្រា២ .-**

ច្បាប់នេះមានគោលដៅកំណត់លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់និងការអនុវត្តអាជ្ញាបណ្ណបញ្ជាសម្រាប់សុខភាពសាធារណៈ ។

**មាត្រា៣ .-**

ច្បាប់នេះមានវិសាលភាពអនុវត្តអាជ្ញាបណ្ណបញ្ជាសម្រាប់សុខភាពសាធារណៈ ពាក់ព័ន្ធនឹងផលិតផលឱសថដែលការពារដោយប្រកាសនីយបត្រតក្កកម្ម ក្នុងកាលៈទេសៈមានភាពអាសន្ន ឬកាលៈទេសៈបន្ទាន់ក្នុងព្រះរាជាណាចក្រកម្ពុជា ។ ការផ្តល់អាជ្ញាបណ្ណបញ្ជាផ្សេងទៀត ដែលមិនស្ថិតនៅក្រោមវិសាលភាពនៃច្បាប់នេះត្រូវស្ថិតនៅក្រោមច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម និងនៅក្រោមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

**មាត្រា៤ .-**

វាក្យសព្ទបច្ចេកទេសសំខាន់ៗ ដែលប្រើក្នុងច្បាប់នេះត្រូវកំណត់និយមន័យដូចតទៅ ៖

១- អាជ្ញាបណ្ណបញ្ជាសម្រាប់សុខភាពសាធារណៈ សំដៅដល់អាជ្ញាបណ្ណដែលផ្តល់ដោយក្រសួងសុខាភិបាល ដែលអនុញ្ញាតឱ្យផលិត ឬនាំចូល ឬនាំចេញនូវផលិតផលឱសថដែលការពារដោយប្រកាសនីយបត្រតក្កកម្ម ដោយមិនចាំបាច់មានការយល់ព្រមពីម្ចាស់ប្រកាសនីយបត្រតក្កកម្ម ។

២- កាលៈទេសៈប្រទេសជាតិមានភាពអាសន្នឬកាលៈទេសៈបន្ទាន់បំផុតផ្សេងទៀត សំដៅដល់ស្ថានភាពដែលប្រទេសជាតិជួបវិបត្តិសុខភាពសាធារណៈ ដែលត្រូវបានប្រកាសដោយក្រសួងសុខាភិបាលទាក់ទងនឹងវិបត្តិនៃការផ្គត់ផ្គង់ផលិតផលឱសថ សម្រាប់ធ្វើរោគវិនិច្ឆ័យ បង្ការ និង/ឬព្យាបាលជំងឺដែលមាន ជាអាទិ៍ អេដស៍ របេង គ្រុនចាញ់ ឬជំងឺផ្សេងទៀត ។

៣- ការប្រើប្រាស់ជាសាធារណៈមិនមានលក្ខណៈពាណិជ្ជកម្ម សំដៅដល់ការប្រើប្រាស់ជាសាធារណៈនូវផលិតផលឱសថទាំងឡាយណាដែលត្រូវបានផលិត នាំចូល នាំចេញ ចែកចាយក្នុងគោលដៅសុខភាពសាធារណៈតាមរយៈសេវាសាធារណៈរបស់រដ្ឋ ឬឯកជន ឬអង្គការមិនមែនរដ្ឋាភិបាល ធ្វើយ៉ាងណាឱ្យអ្នកប្រើប្រាស់អាចទទួលយកបានឱសថនោះ ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

៤- ប្រកាសនីយបត្រតក្កកម្ម សំដៅដល់វិញ្ញាបនបត្រដែលចេញដោយក្រសួងទទួលបន្ទុកឧស្សាហកម្ម សម្រាប់ការពារតក្កកម្មដែលកំណត់នៅក្នុងច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្មដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០៣/០០៥ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០៣ ។

៥- អ្នកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណបញ្ញា សំដៅដល់ស្ថាប័នសាធារណៈរបស់រដ្ឋឬឯកជន អង្គការជាតិ ឬអន្តរជាតិ ដែលទទួលស្គាល់ដោយក្រសួងសុខាភិបាលនិងត្រូវបានអនុញ្ញាតឱ្យផលិត ឬនាំចូល ឬនាំចេញ ឬចែកចាយផលិតផលឱសថ ។

៦- ប្រទេសជាសមាជិកមានសិទ្ធិនាំចេញ សំដៅដល់ប្រទេសជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ដែលប្រើប្រាស់សេចក្តីសម្រេចរបស់អគ្គក្រុមប្រឹក្សា សម្រាប់នាំចេញផលិតផលឱសថទៅប្រទេសជាសមាជិកមានសិទ្ធិនាំចូល ។

៧- ប្រទេសជាសមាជិកមានសិទ្ធិនាំចូល សំដៅដល់ ៖

- ប្រទេសជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោកដែលមានការអភិវឌ្ឍតិចតួច ឬ
- ប្រទេសជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោកដែលបានជូនដំណឹងទៅអគ្គក្រុមប្រឹក្សានៃកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញាអំពីបំណងរបស់ខ្លួនក្នុងការប្រើប្រាស់សេចក្តីសម្រេចរបស់អគ្គក្រុមប្រឹក្សាក្នុងនាមជាប្រទេសមានសិទ្ធិនាំចូល ឬ
- ប្រទេសដែលមិនមែនជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក ប៉ុន្តែបានផ្តល់សេចក្តីជូនដំណឹងជាផ្លូវការទៅព្រះរាជាណាចក្រកម្ពុជាថានឹងអនុវត្តទៅតាមលក្ខខណ្ឌនានាដែលមានចែងនៅក្នុងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា ព្រមទាំងបានផ្សព្វផ្សាយជាសាធារណៈលើគេហទំព័ររបស់ខ្លួននូវរាល់សេចក្តីជូនដំណឹងទាំងឡាយដែលតម្រូវដោយសេចក្តីសម្រេចរបស់អគ្គក្រុមប្រឹក្សា ។

៨- ផលិតផលឱសថ សំដៅដល់ឱសថដូចមានចែងក្នុងនិយមន័យនៃច្បាប់ស្តីពីការគ្រប់គ្រងឱសថ និងការពារដោយប្រកាសនីយបត្រតក្កកម្ម ឬផលិតផលឱសថដែលដំណើរការផលិតកម្មត្រូវបានការពារដោយប្រកាសនីយបត្រតក្កកម្ម នៅក្នុងវិស័យឱសថនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬនៅប្រទេសនាំចេញមកព្រះរាជាណាចក្រកម្ពុជា ដោយរាប់បញ្ចូលនូវសារធាតុសកម្មនិងសម្ភារៈប្រតិករសម្រាប់ការវិភាគផលិតផលនោះ ។

៩- សេចក្តីសម្រេចរបស់អគ្គក្រុមប្រឹក្សា សំដៅដល់ការអនុវត្តកថាខណ្ឌទី៦នៃសេចក្តីប្រកាសទីក្រុងដូហាស្តីពីកិច្ចព្រមព្រៀងពាណិជ្ជកម្មពាក់ព័ន្ធកម្មសិទ្ធិបញ្ញា និងសុខភាពសាធារណៈដែលអនុម័តដោយអគ្គក្រុមប្រឹក្សានៃអង្គការពាណិជ្ជកម្មពិភពលោក ។

## ជំពូកទី ២
## សមត្ថកិច្ច

**មាត្រា៥ .-**

ក្រសួងសុខាភិបាលក្នុងនាមរាជរដ្ឋាភិបាលកម្ពុជាជាស្ថាប័នមានសមត្ថកិច្ច ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

- គ្រប់គ្រង ចាត់ចែង និងត្រួតពិនិត្យអាជ្ញាបណ្ណបញ្ញាតាមបទប្បញ្ញត្តិនៃច្បាប់នេះ
- កំណត់នូវលក្ខខណ្ឌ បែបបទនិងនីតិវិធីក្នុងការផ្តល់អាជ្ញាបណ្ណបញ្ញា
- កំណត់ពីកាលៈទេសៈប្រទេសជាតិមានភាពអាសន្ន ឬកាលៈទេសៈបន្ទាន់បំផុត និង/ឬការប្រើប្រាស់ជាសាធារណៈមិនមានលក្ខណៈពាណិជ្ជកម្មលើសុខភាពសាធារណៈ
- កំណត់លក្ខខណ្ឌអំពីការអនុវត្តអាជ្ញាបណ្ណបញ្ញា

លក្ខខណ្ឌនិងកាលៈទេសៈខាងលើនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

**មាត្រា៦ .-**

ក្រសួងពាណិជ្ជកម្ម ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ជាស្ថាប័នមានសមត្ថកិច្ចក្នុងការជូនដំណឹងទៅអគ្គក្រុមប្រឹក្សាអង្គការពាណិជ្ជកម្មពិភពលោក ស្តីអំពីការផ្តល់អាជ្ញាបណ្ណបញ្ញាសម្រាប់នាំចេញឬនាំចូលផលិតផលឱសថ ។

**មាត្រា៧ .-**

អ្នកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណបញ្ញា ដែលមានបំណងនាំចូលផលិតផលឱសថមកក្នុងព្រះរាជាណាចក្រកម្ពុជាអាចស្នើសុំជំនួយពីក្រសួងមានសមត្ថកិច្ចក្នុងការបំពេញលក្ខខណ្ឌតម្រូវផ្នែកច្បាប់របស់ប្រទេសជាសមាជិកមានសិទ្ធិនាំចេញ ។

**មាត្រា៨ .-**

ក្រសួងសុខាភិបាលត្រូវរៀបចំឱ្យមានលេខាធិការដ្ឋានទទួលបន្ទុកអាជ្ញាបណ្ណបញ្ញាដើម្បីដំណើរការអនុវត្តអាជ្ញាបណ្ណបញ្ញា និងដោះស្រាយសម្របសម្រួលបណ្តឹងតវ៉ាក្នុងករណីមានវិវាទពាក់ព័ន្ធអាជ្ញាបណ្ណបញ្ញានេះ ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានអាជ្ញាបណ្ណបញ្ញា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

## ជំពូកទី ៣

## លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់អាជ្ញាបណ្ណបញ្ញា

**មាត្រា៩ .-**

ការផ្តល់អាជ្ញាបណ្ណបញ្ញាសម្រាប់នាំចូល ផលិត និងនាំចេញត្រូវគោរពតាមលក្ខខណ្ឌដូចខាងក្រោម ៖

១- អាជ្ញាបណ្ណបញ្ញាមិនត្រូវមានសិទ្ធិផ្តាច់មុខឡើយ ។

២- អាជ្ញាបណ្ណបញ្ញាមិនអាចត្រូវបានផ្ទេរសិទ្ធិឡើយលើកលែងតែផ្ទេរជូនទៅផ្នែកណាមួយនៃនីតិបុគ្គលដែលមានសិទ្ធិប្រើប្រាស់អាជ្ញាបណ្ណបញ្ញានេះ ។

៣- ក្នុងរយៈពេល ២១ ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីផ្តល់អាជ្ញាបណ្ណបញ្ញា ក្រសួងសុខាភិបាលត្រូវជូនដំណឹងទៅម្ចាស់ប្រកាសនីយបត្រតក្កកម្មថា អាជ្ញាបណ្ណបញ្ញាមួយត្រូវបានចេញតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

៤- ការផ្តល់អាជ្ញាបណ្ណបញ្ញាសម្រាប់នាំចូល ឬផលិត ឬនាំចេញមិនតម្រូវឱ្យមានការព្រមព្រៀងជាមុនពីម្ចាស់ប្រកាសនីយបត្រតក្កកម្មឡើយ ។

៥- ក្រសួងសុខាភិបាលត្រូវផ្តល់អាជ្ញាបណ្ណបញ្ញាសម្រាប់នាំចេញ នាំចូល ឬផលិតក្នុងស្រុកនូវផលិតផលឱសថណាមួយក្រោយពេលមានការស្នើសុំដែលបានបំពេញនូវរាល់លក្ខខណ្ឌតម្រូវរបស់ច្បាប់នេះ ។

៦- ការផ្តល់អាជ្ញាបណ្ណបញ្ញាសម្រាប់នាំចូលឬផលិតក្នុងស្រុកធ្វើឡើងក្នុងកាលៈទេសៈប្រទេសជាតិមានភាពអាសន្ន ឬកាលៈទេសៈបន្ទាន់បំផុតផ្សេងទៀត ឬការប្រើប្រាស់ជាសាធារណៈមិនមានលក្ខណៈពាណិជ្ជកម្ម ឬស្ថានភាពសុខភាពសាធារណៈផ្សេងទៀតដែលកំណត់ដោយក្រសួងសុខាភិបាល ។

ការផ្តល់អាជ្ញាបណ្ណបញ្ញាសម្រាប់នាំចូល ឬផលិតក្នុងស្រុកគឺសម្រាប់ផ្គត់ផ្គង់បរិមាណឱសថឱ្យបានបរិបូរណ៍ដល់ទីផ្សារនៃព្រះរាជាណាចក្រកម្ពុជា ។

៧- ការផ្តល់អាជ្ញាបណ្ណបញ្ញាសម្រាប់នាំចេញទៅប្រទេសជាសមាជិកមានសិទ្ធិនាំចូល គឺធ្វើឡើងក្នុងបរិមាណ និងស្ថានភាពប្រើប្រាស់ដូចមានចែងនៅចំណុច "៦" នៃមាត្រានេះដោយចាត់ទុកស្ថានភាពនេះហាក់បីដូចជាកើតមានឡើងក្នុងព្រះរាជាណាចក្រកម្ពុជាដែរ ។

**មាត្រា១០ .-**

ការផ្តល់អាជ្ញាបណ្ណបញ្ញាត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម ៖

១- ពាក្យស្នើសុំអាជ្ញាបណ្ណបញ្ញាត្រូវយកមកធ្វើការពិនិត្យនៅក្រោយពេលដែលក្រសួងសុខាភិបាលបានផ្ទៀងផ្ទាត់ឃើញថា អ្នកស្នើសុំបានបំពេញត្រឹមត្រូវតាមទម្រង់បែបបទដែលតម្រូវដោយច្បាប់នេះ ។

២- ក្រសួងសុខាភិបាលត្រូវជូនដំណឹងទៅអ្នកដាក់ពាក្យស្នើសុំជាលាយលក្ខណ៍អក្សរអំពីសេចក្តីសម្រេចរបស់ខ្លួនថា ឯកភាពផ្តល់ឱ្យឬមិនឯកភាពផ្តល់ឱ្យ ក្នុងរយៈពេល ២១ ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលបានទទួលពាក្យស្នើសុំត្រឹមត្រូវ ។

៣- ក្នុងករណីមិនឯកភាពផ្តល់អាជ្ញាបណ្ណបញ្ញា ក្រសួងសុខាភិបាលត្រូវបញ្ជាក់ពីមូលហេតុឱ្យបានច្បាស់លាស់ជាលាយលក្ខណ៍អក្សរជូនដំណឹងទៅអ្នកដាក់ពាក្យស្នើសុំ ។ អ្នកដាក់ពាក្យស្នើសុំមានសិទ្ធិដាក់ពាក្យទៅលេខាធិការដ្ឋានទទួលបន្ទុកអាជ្ញាបណ្ណបញ្ញា ដើម្បីផ្សះផ្សាសម្របសម្រួលមុនពេលប្តឹងទៅតុលាការមានសមត្ថកិច្ច ។ អ្នកដាក់ពាក្យស្នើសុំអាចប្តឹងតុលាការមានសមត្ថកិច្ចឱ្យពិនិត្យសើរើលើសេចក្តីសម្រេចមិនឯកភាពផ្តល់អាជ្ញាបណ្ណបញ្ញានេះ ។

៤- ក្នុងករណីពិសេសចាំបាច់ ក្រសួងសុខាភិបាលអាចជ្រើសតាំងនីតិបុគ្គលណាមួយដើម្បីផ្តល់អាជ្ញាបណ្ណបញ្ញាឱ្យផលិត ឬនាំចូលផលិតផលឱសថនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

៥- បែបបទនិងនីតិវិធីក្នុងការផ្តល់អាជ្ញាបណ្ណបញ្ញា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា១១ .-**

ការផលិត ការនាំចូល ការនាំចេញផលិតផលឱសថក្រោមអាជ្ញាបណ្ណបញ្ញាតម្រូវឱ្យមានការបង់ប្រាក់កម្រៃទៅឱ្យម្ចាស់ប្រកាសនីយបត្រតក្កកម្ម ។

ការបង់កម្រៃត្រូវលើកលែងចំពោះការនាំចូល ក្នុងករណីប្រាក់កម្រៃនេះត្រូវបានបង់រួចហើយនៅប្រទេសមានសិទ្ធិនាំចេញ ។

នីតិវិធីនិងលក្ខណវិនិច្ឆ័យនៃអត្រាកម្រៃដែលត្រូវបង់ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា១២ .-**

ក្រសួងពាណិជ្ជកម្មមានភារកិច្ចជូនដំណឹងដល់អគ្គក្រុមប្រឹក្សាអង្គការពាណិជ្ជកម្មពិភពលោកអំពីការនាំចូលដោយផ្អែកតាមព័ត៌មានដែលផ្តល់ឱ្យដោយក្រសួងសុខាភិបាល ៖

- បញ្ជាក់ពីឈ្មោះ បរិមាណនៃផលិតផលឱសថដែលបានគ្រោងទុកនិងដែលត្រូវការចាំបាច់
- បញ្ជាក់ថារាជរដ្ឋាភិបាលកម្ពុជាបានផ្តល់ឬមានបំណងផ្តល់នូវអាជ្ញាបណ្ណបញ្ញាសម្រាប់ដោះស្រាយភាពអាសន្នផ្នែកសុខភាពរបស់ជាតិ ឬភាពបន្ទាន់បំផុតផ្នែកសុខភាពរបស់ជាតិ ឬសម្រាប់ប្រើប្រាស់ជាសាធារណៈមិនមានលក្ខណៈពាណិជ្ជកម្ម ប្រសិនបើផលិតផលឱសថត្រូវបានការពារដោយប្រកាសនីយបត្រតក្កកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា១៣ .-**

ក្រសួងពាណិជ្ជកម្មមានភារកិច្ចជូនដំណឹងដល់អគ្គក្រុមប្រឹក្សាអំពីការនាំចេញដោយ ៖

១- បញ្ជាក់ពីឈ្មោះនិងអាស័យដ្ឋាននៃអ្នកទទួលបានអាជ្ញាបណ្ណបញ្ញា

២- បញ្ជាក់ពីផលិតផលឱសថដែលបានផ្តល់ឱ្យតាមរយៈអាជ្ញាបណ្ណបញ្ញា

៣- បញ្ជាក់ពីបរិមាណដែលបានផ្តល់ឱ្យដោយអាជ្ញាបណ្ណបញ្ញា

៤- បញ្ជាក់ពីប្រទេសឬបណ្តាប្រទេសដែលត្រូវនាំចេញផលិតផលឱសថ

៥- បញ្ជាក់ពីអាសយដ្ឋាននៃគេហទំព័ររបស់អ្នកទទួលបានអាជ្ញាបណ្ណបញ្ញា

៦- បញ្ជាក់ពីសុពលភាពនៃអាជ្ញាបណ្ណបញ្ញា

៧- បញ្ជាក់ពីលក្ខខណ្ឌផ្សេងទៀតដែលទាក់ទងនឹងអាជ្ញាបណ្ណបញ្ញាដូចមានបញ្ជាក់នៅក្នុងចំណុច "២" នៃមាត្រា៩នៃច្បាប់នេះ ។

**មាត្រា១៤ .-**

ការស្នើសុំអាជ្ញាបណ្ណបញ្ញានាំចេញផលិតផលឱសថពីព្រះរាជាណាចក្រកម្ពុជាត្រូវមានឯកសារបញ្ជាក់របស់ប្រទេសមានសិទ្ធិនាំចូលដូចខាងក្រោម ៖

១- លិខិតបញ្ជាក់ពីបំណងនៃការនាំចូលផលិតផលឱសថ និង/ឬលិខិតបញ្ជាក់កស្តុតាងផ្សេងៗដើម្បីគាំទ្រដល់ការស្នើសុំនេះ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

២- លិខិតចំលងចម្លងនៃសេចក្តីជូនដំណឹងទៅអង្គការពាណិជ្ជកម្មពិភពលោកពីបំណងរបស់ខ្លួន បើសិនជាប្រទេសនោះមានការអភិវឌ្ឍតិចតួច និងមិនមែនជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក

៣- លិខិតចំលងចម្លងបញ្ជាក់ទៅអង្គការពាណិជ្ជកម្មពិភពលោកពីការសន្យាជាផ្លូវការចំពោះព្រះរាជាណាចក្រកម្ពុជាថា ខ្លួននឹងអនុវត្តទៅតាមលក្ខខណ្ឌនានាដែលមានចែងនៅក្នុងសេចក្តីសម្រេចរបស់អគ្គក្រុមប្រឹក្សា ព្រមទាំងផ្សព្វផ្សាយជាសាធារណៈលើគេហទំព័ររបស់ខ្លួន នូវរាល់សេចក្តីជូនដំណឹងទាំងឡាយដែលតម្រូវឱ្យមានក្រោមវាក្យខណ្ឌ 1(b) និង2(a) នៃសេចក្តីសម្រេចរបស់អគ្គក្រុមប្រឹក្សា បើសិនជាប្រទេសនោះមិនមែនជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក ។

**មាត្រា១៥ .–**

ការផ្តល់អាជ្ញាបណ្ណបញ្ជាសម្រាប់ការនាំចេញ ត្រូវគោរពតាមលក្ខខណ្ឌដូចតទៅ ៖

១- បរិមាណនៃផលិតផលឱសថត្រូវកំណត់ត្រឹមតែតម្រូវការចាំបាច់នៃប្រទេសជាសមាជិកមានសិទ្ធិនាំចូលដោយរួមបញ្ចូលទាំងបរិមាណសម្រាប់ធ្វើការត្រួតពិនិត្យគុណភាព និងការសុំអនុញ្ញាតតាមផ្លូវច្បាប់ផងដែរ ។

២-រាល់ផលិតផលឱសថទាំងអស់ដែលនាំចេញតាមអាជ្ញាបណ្ណបញ្ជា ត្រូវតែមានការកំណត់ឱ្យបានច្បាស់លាស់ដោយមានស្លាកសញ្ញានិងលក្ខណៈពិសេសងាយសម្គាល់តាមរយៈការវេចខ្ចប់ ពណ៌ រូបរាងដែលអាចធ្វើទៅបានដោយមិនប៉ះពាល់ដល់តម្លៃនៃផលិតផលនោះ ។

៣- មុនធ្វើការនាំចេញផលិតផលឱសថ អ្នកទទួលបានអាជ្ញាបណ្ណបញ្ជាត្រូវតែធ្វើការផ្សព្វផ្សាយតាមគេហទំព័ររបស់ខ្លួន ឬគេហទំព័រដែលរៀបចំឡើងដោយអង្គការពាណិជ្ជកម្មពិភពលោកនូវ ៖

- បរិមាណនៃផលិតផលឱសថដែលត្រូវនាំចេញ
- កំណត់សម្គាល់លក្ខណៈពិសេសដូចមានចែងក្នុងចំណុច "២" ខាងលើនេះ ។

ក្នុងករណីដែលប្រទេសមានសិទ្ធិនាំចូលត្រូវការផ្គត់ផ្គង់ផលិតផលឱសថក្នុងបរិមាណបន្ថែមទៀត ក្រសួងសុខាភិបាលត្រូវអនុញ្ញាតតាមការស្នើសុំរបស់អ្នកទទួលបានអាជ្ញាបណ្ណបញ្ជា ដោយគោរពតាមមាត្រា១៣ និងរាល់លក្ខខណ្ឌនៃច្បាប់នេះ ។

**មាត្រា១៦ .–**

តាមការស្នើសុំរបស់ម្ចាស់ប្រកាសនីយបត្រតក្កកម្ម ក្រសួងសុខាភិបាលអាចពិនិត្យឡើងវិញអំពីនិរន្តរភាពនៃអាជ្ញាបណ្ណបញ្ជា ៖

- បន្ទាប់ពីរយៈពេល ២(ពីរ)ឆ្នាំដោយគិតចាប់ពីពេលអនុញ្ញាតឱ្យមានលើទីផ្សារនូវផលិតផលឱសថដែលផលិតក្នុងស្រុក ឬនាំចូលក្រោមអាជ្ញាបណ្ណបញ្ជា ឬគិតចាប់ពីកាលបរិច្ឆេទនៃការនាំចេញនូវផលិតផលឱសថដែលបាននាំចេញ ឬ
- នៅក្នុងករណីដែលមូលហេតុនៃការផ្តល់អាជ្ញាបណ្ណបញ្ជាលែងមានតទៅទៀត ឬទំនងជាមិនអាចកើតឡើងជាថ្មីម្តងទៀត ។

ការពិនិត្យឡើងវិញនេះ ត្រូវពិចារណាដល់ការការពារគ្រប់គ្រាន់នូវផលប្រយោជន៍ស្របច្បាប់របស់អ្នកទទួលបានអាជ្ញាបណ្ណបញ្ញានោះ ។

ប្រសិនបើការស្នើសុំឱ្យពិនិត្យឡើងវិញត្រូវបានបដិសេធឬប្រសិនបើគ្មានការជូនដំណឹងអំពីសេចក្ដីសម្រេចណាមួយដល់ម្ចាស់ប្រកាសនីយបត្រតក្កកម្មក្នុងរយៈពេល ៩០(កៅសិប)ថ្ងៃគិតចាប់ពីកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំ ម្ចាស់ប្រកាសនីយបត្រតក្កកម្មអាចដាក់ពាក្យស្នើសុំឱ្យពិនិត្យឡើងវិញទៅតុលាការមានសមត្ថកិច្ចបាន ។

ពាក្យស្នើសុំឱ្យពិនិត្យឡើងវិញទៅក្រសួងសុខាភិបាល ឬទៅតុលាការមានសមត្ថកិច្ចនេះមិនអាចមានប្រសិទ្ធភាពព្យួរការអនុវត្តអាជ្ញាបណ្ណបញ្ញាដែលផ្ដល់ឱ្យក្រោមច្បាប់នេះឡើយ ។

**មាត្រា១៧ .-**

ការការពារដែលបានផ្ដល់ចំពោះទិន្នន័យសម្រាប់ធ្វើតេស្ត ឬព័ត៌មានសម្ងាត់ផ្សេងៗទៀតមិនត្រូវយកមកប្រើដើម្បីរាំងបង្អាក់ ឬពន្យឺតពេលអនុវត្តអាជ្ញាបណ្ណបញ្ញាដែលបានផ្ដល់ក្រោមច្បាប់នេះឡើយ ។

**មាត្រា១៨ .-**

ក្រសួងសុខាភិបាលត្រូវកំណត់ពីលក្ខខណ្ឌតម្រូវនានា សម្រាប់វាយតម្លៃគុណភាព សុវត្ថិភាព និងប្រសិទ្ធភាពរបស់ផលិតផលឱសថដែលនឹងត្រូវបាននាំចូល ផលិត និងនាំចេញ ក្រោមអាជ្ញាបណ្ណបញ្ញាដោយពិចារណាលើកាលៈទេសៈនានាដែលតម្រូវឱ្យ។

បែបបទ នីតិវិធី និងលក្ខខណ្ឌតម្រូវទាំងនេះត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

## ជំពូកទី៤

## ទោសប្បញ្ញត្តិ

**មាត្រា១៩ .-**

រាល់ការចែកចាយដោយខុសច្បាប់នូវផលិតផលឱសថដែលនាំចូលឬផលិតនៅក្រោមច្បាប់នេះត្រូវផ្ដន្ទាទោសតាមច្បាប់ជាធរមានរបស់ព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា២០ .-**

ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់មិនលើសពី ១០ ០០០ ០០០(ដប់លានរៀល) ចំពោះជនណាដែល ៖

១- នាំចូល នាំចេញ ឬផលិតនៅក្រោមច្បាប់នេះ នូវផលិតផលឱសថដោយគ្មានអាជ្ញាបណ្ណបញ្ញាសម្រាប់ សុខភាពសាធារណៈ ។

២- ផ្ទេរសិទ្ធិប្រើប្រាស់អាជ្ញាបណ្ណបញ្ញាសម្រាប់សុខភាពសាធារណៈទៅបុគ្គលដែលគ្មានសិទ្ធិ ។

ក្នុងករណីដែលទទួលរងនូវការពិន័យអន្តរការណ៍ម្តងរួចហើយ តែនៅបន្តប្រព្រឹត្តបទល្មើសដដែលទៀត ត្រូវពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង ។

**មាត្រា២១ .-**

នីតិបុគ្គលអាចត្រូវប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌចំពោះបទល្មើសដែលមានចែងក្នុងមាត្រា២០ នៃច្បាប់នេះ ។

នីតិបុគ្គលត្រូវពិន័យជាប្រាក់ទ្វេដងព្រមទាំងទោសបន្ថែមណាមួយឬច្រើនដូចតទៅនេះ ៖

១-ការរំលាយតាមបែបកំណត់ដោយមាត្រា១៧០ (ការរំលាយនិងការជម្រះបញ្ជីនៃនីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ ។

២- ការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យតាមដានរបស់តុលាការតាមបែបបទកំណត់ដោយមាត្រា១៧១ (ការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យតាមដានរបស់តុលាការ)នៃក្រមព្រហ្មទណ្ឌ ។

៣- ការហាមឃាត់ចំពោះការធ្វើសកម្មភាពណាមួយឬច្រើនតាមបែបបទកំណត់ដោយមាត្រា១៧២ (ការហាមឃាត់ចំពោះការធ្វើសកម្មភាព)នៃក្រមព្រហ្មទណ្ឌ ។

៤- ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោសតាមបែបបទកំណត់ដោយមាត្រា១៨០ (ការបិទផ្សាយសេចក្តីសម្រេច)នៃក្រមព្រហ្មទណ្ឌ ។

៥- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរឬការផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍តាមបែបបទកំណត់ដោយមាត្រា១៨១ (ការផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ជាអាទិ៍)នៃក្រមព្រហ្មទណ្ឌ ។

**មាត្រា២២ .-**

ការពិន័យអន្តរការណ៍ដែលកំណត់ដោយច្បាប់នេះ ជាសមត្ថកិច្ចរបស់ភ្នាក់ងារសុខាភិបាលមាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ។

ក្នុងករណីរឹងរូសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ក្រសួងសុខាភិបាលត្រូវកសាងសំណុំរឿងបញ្ជូនទៅតុលាការតាមនីតិវិធី ។

**មាត្រា២៣ .-**

នីតិវិធីក្នុងការពិន័យអន្តរការណ៍ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា២៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ថ្ងៃ សុក្រ ១៣កើត ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១៨

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស.រកម.០៤១៨.០២០

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**
**ហត្ថលេខា**
**ម៉ម ប៊ុនហេង**

លេខ: ៤៧៣ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
ថ្ងៃពុធ ៣រោច ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ២០១៨
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**[illegible] សុខា**